**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៥៧ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការដើម្បីអនុវត្តទិដ្ឋាការតែមួយ អេកម៉ិកកម្ពុជា_ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ស ម្រេ ច

**ប្រការ ១ :** បង្កើតគណៈកម្មការមួយដែលមានឈ្មោះថា **"គណៈកម្មការដើម្បីអនុវត្តទិដ្ឋាការតែមួយកម្ពុជា_ថៃ** (Single Visa) **ក្នុងក្របខ័ណ្ឌ** ACMECS" ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១- ឯកឧត្ដម | **ហង់ ជួនណារ៉ុន** | អគ្គលេខាធិការគណៈកម្មការទទួលបន្ទុកកិច្ចការអេកម៉ិក | ប្រធាន |
| ២- លោក | **ហោ មុនីរត្ន** | ប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុលនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣- លោក | **ឌិត្ស ចន្ថា** | អគ្គនាយករងនៃក្រសួងទេសចរណ៍ | សមាជិក |
| ៤- លោក | **អ៊ូន ម៉ិនហាក់** | ប្រធាននាយកដ្ឋានចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- លោក | **ពុំ វិត្សា** | អនុប្រធាននាយកដ្ឋានជនបរទេសនៃក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ចដូចតទៅ :

- រៀបចំមូលដ្ឋានបច្ចេកទេស ដើម្បីដាក់អោយអនុវត្តនូវទិដ្ឋាការតែមួយកម្ពុជា-ថៃ

- រៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ដើម្បីសម្រួលដល់ការអនុវត្តទិដ្ឋាការតែមួយកម្ពុជា-ថៃ
- ពិភាក្សាជាមួយភាគីថៃ ដើម្បីជំរុញការអនុវត្តគំរោងទិដ្ឋាការតែមួយកម្ពុជា-ថៃ ស្របតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីទិដ្ឋាការតែមួយក្នុងក្របខ័ណ្ឌអេកម៉ិក
- ពិភាក្សាជាមួយភាគីថៃ ដើម្បីពិនិត្យនិងតាមដានរួមគ្នាអំពីការអនុវត្តទិដ្ឋាការតែមួយកម្ពុជា-ថៃ
- ទំនាក់ទំនងជាមួយស្ថានទូតឡាវ មីយ៉ាន់ម៉ា និង វៀតណាម នៅភ្នំពេញ ដើម្បីពិភាក្សាជំរុញអោយមានការចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាជាបន្តបន្ទាប់
- តាមការទូទាត់ចំណូលនៃទិដ្ឋាការតែមួយ កម្ពុជា-ថៃ
- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ស្តីពីលទ្ធផលនៃដំណើរការទូទាត់ចំណូលទិដ្ឋាការតែមួយកម្ពុជា-ថៃ ។

**ប្រការ ៣** : គណៈកម្មការនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធនឹងការងារទូទាត់ចំណូលទិដ្ឋាការតែមួយកម្ពុជា-ថៃ ក្នុងក្របខ័ណ្ឌអេកម៉ិក ដើម្បីចូលរួមបំពេញការងារតាមការជាក់ស្តែង ។

**ប្រការ ៤** : សមាជិកទាំងអស់នៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំ និងធ្វើការងារតាមសេចក្តីអញ្ជើញ និងការណែនាំរបស់ប្រធាន ។

**ប្រការ ៥** : គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជាផ្លូវការ ។
គណៈកម្មការនេះ មានលេខាធិការដ្ឋានមួយដែលស្ថិតនៅក្នុងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**ប្រការ ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្ត សេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល:**
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចប្រការ៦
ឯកសារ-កាលប្បវត្តិ